# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា

## ការិយាល័យ អគ្គនាយក

**440 NORTH BROAD STREET, SUITE 301**
**PHILADELPHIA, PENNSYLVANIA 19130**

**WILLIAM R. HITE, JR., Ed.D.**
*អគ្គនាយក*


ថ្ងៃទី ៦ ខែមីនា ឆ្នាំ ២០១៨

ជូនចំពោះ មាតាបិតា និង អាណាព្យាបាល ជាទីគោរព៖

ដោយសារសោកនាដកម្មនៃការបាញ់ប្រហារនៅសាលារៀន នៅរដ្ឋ ហ្វ្លរីដា ក្នុងពេលថ្មីៗនេះ សិស្សានុសិស្សទូទាំងប្រទេសកំពុងព្យាយាមរកវិធីដ៏ល្អដើម្បីដោះស្រាយជាមួយនឹងហេតុការណ៍ដ៏រន្ធត់នេះ។ ជាលទ្ធផល នៅថ្ងៃទី ១៤ ខែមីនា សិស្សានុសិស្សនៅគ្រប់ទិសទីទូទាំងប្រទេសគ្រោងនឹងដើរចេញពីសាលារៀនរយៈពេល ១៧ នាទី ដើម្បីបង្ហាញពីសាមគ្គីភាពជាមួយសិស្សានុសិស្សនៅរដ្ឋ ហ្វ្លរីដា ដើម្បីអំពាវនាវឲ្យមានការកែលម្អច្បាប់ គ្រប់គ្រងកាំភ្លើង និងដើម្បីជាការរំឭកឲ្យបានដឹងអំពីបញ្ហាហិង្សាដោយកាំភ្លើង នៅក្នុងសហគមន៍ និងនៅសាលារៀន។

នៅក្នុងការចូលរួមជាមួយនឹងចលនាទូទាំងប្រទេសនេះ សិស្សានុសិស្សដែលសម្រេចថានឹងដើរចេញពីសាលា ត្រូវបានគេផ្តល់កន្លែងសម្រាប់ធ្វើការប្រមូលផ្តុំនៅកន្លែងមួយដែលគេបានកំណត់ ធ្វើបែបនេះការដើរចេញពីសាលាណាមួយនឹងប្រព្រឹត្តទៅតាមរបៀបរៀបរយនិងមានសុវត្ថិភាព។ ទោះជាយ៉ាងណាក៏ដោយ សាលានឹងមិន ជំរុញ ឬ បង្អាក់ មិនឲ្យសិស្សដើរចេញ ឬក៏ហាមឃាត់សិស្សក្នុងការចូលរួម ឬដាក់វិន័យ បើសិនជាពួកគេធ្វើ ទេ។ សកម្មភាពផ្សេងៗនឹងបន្តជាធម្មតាក្នុងអំឡុងពេលគេដើរចេញពីសាលា ហើយសិស្សានុសិស្សដែលចូលរួមព្រឹត្តិការណ៍នេះ ត្រូវបានគេរំពឹងថានឹងចូលក្នុងអាគារវិញបន្ទាប់ពីការដើរចេញនេះចប់។

យើងទទួលស្គាល់ថា មានការយកចិត្តទុកដាក់ និង ទស្សនៈ ផ្សេងៗគ្នា អំពីវិធីដែលប្រទេសនេះគប្បីប្រតិកម្មតបនឹងសោកនាដកម្មនេះ ហើយដឹងថាសិស្សខ្លះមិនចង់ចូលរួមក្នុងការដើរចេញនេះទេ ហើយចង់នៅក្នុងថ្នាក់រៀន។ យើងធានាចំពោះ សិស្ស និង ក្រុមគ្រួសារ របស់យើងថា យើងនឹងធ្វើយ៉ាងណាឲ្យសិស្សទាំងអស់ មានសុវត្ថិភាព និង មានការគោរព ទោះជាពួកគេជ្រើសរើសវិធីណាក៏ដោយ។ ជានិច្ចជាកាល សុវត្ថិភាពរបស់សិស្សយើង គឺជាការយកចិត្តទុកដាក់ខ្ពស់បំផុតរបស់យើង។

ក្នុងនាមជាក្រសួងអប់រំ យើងលើកទឹកចិត្តឲ្យសិស្សានុសិស្សធ្វើជាប្រជាពលរដ្ឋសកម្ម ដែលមានចំណេះដឹងអំពីព្រឹត្តិការណ៍ថ្មីៗ។ នេះអាចជាឱកាសឲ្យសិស្សរបស់យើង យកមេរៀនដែលពួកគេបានរៀននៅក្នុងសាលាមកអនុវត្ត។ សំខាន់ជាងនេះទៅទៀត យើងចង់ឲ្យពួកគេដឹងថា យើងផ្តល់តម្លៃដល់ មតិ និង ការប្រើសិទ្ធិរបស់ពួកគេ។ ដើម្បីសម្រេចគោលបំណងនេះ យើងបានផ្តល់នូវប្រភពជំនួយសម្រាប់ថ្នាក់ដឹកនាំរបស់សាលា ដើម្បីរៀបចំសកម្មភាពនៅក្នុងសាលា និង/ឬ សកម្មភាពដែលអនុញ្ញាតឲ្យសិស្សបញ្ចេញ មតិ និង ទស្សនៈ របស់ពួកគេ ដែលគាំទ្រដល់ ព្រឹត្តិការណ៍ដើរចេញ ឬក៏ជាជម្រើសផ្សេងទៀត ក្នុងខណៈដែលយើងធានានូវសុវត្ថិភាពរបស់ពួកគេ។

ឧបទ្ទវហេតុនេះ បានបញ្ជាក់ពីតម្រូវការសម្រាប់យើងទាំងអស់គ្នា ដែលជាសហគមន៍របស់សាលា ធ្វើការជាមួយគ្នាដើម្បីធានានូវសុវត្ថិភាពសម្រាប់ សាលា និងតំបន់ របស់យើង។ សូមចំណាយពេលនិយាយជាមួយកូនរបស់លោកអ្នកអំពីផលវិបាកធ្ងន់ធ្ងរ ដំពោះការនាំយកអាវុធប្រភេទអ្វីមួយទៅសាលា។ វាជាការសំខាន់ណាស់ដែលក្មេងដឹងថា បើសិនជាពួកគេត្រូវការជំនួយ ឬមានការព្រួយបារម្ភ អំពីសុវត្ថិភាពផ្ទាល់ខ្លួនរបស់ពួកគេ ត្រូវទាក់ទងជាមួយបុគ្គលិកសាលា ឬ ភ្នាក់ងារប៉ូលីស ភ្លាមៗ។ ការគាំទ្រដល់កូនៗរបស់យើង ដោយ ការសន្ទនាជាវិជ្ជមាន និង បើកចំហ មានសារៈសំខាន់ក្នុងការជួយពួកគេដោះស្រាយភាពស្រពេចស្រពិល។

សូមចងចាំថា បើសិនជាកូនរបស់លោកអ្នក បានឃើញអ្វី ត្រូវនិយាយប្រាប់គេ! មានវិធីពីរដើម្បីរាយការណ៍៖
ទូរស័ព្ទ៖ ២១៥-៤០០-៧២៣៣ ឬ អ៊ីមែល៖ ask@philasd.org

យើងនឹងបន្តបង្កើតបរិយាកាសសិក្សាប្រកបដោយ សុវត្ថិភាព និង វិជ្ជមាន បំផុតសម្រាប់កូនរបស់លោកអ្នក។

ដោយសេចក្តីស្មោះស្ម័គ្រ

William R. Hite, Jr., Ed.D.